## ខ្លឹមសារសង្ខេបសាលដីកាលេខ៣៦(២០១៧)

### ពាក្យគន្លឹះ

លួចមានស្ថានទម្ងន់, សំអាងហេតុ, ទោសកម្រិតអប្បបរមា

### ១.ប្រវត្តិនីតិវិធីនិងសេចក្តីសម្រេច

ខែធ្នូ ឆ្នាំ២០១៥ វេលាយប់ មានទង្វើលួចយកម៉ូតូមួយគ្រឿង ប្រព្រឹត្តនៅ ខណ្ឌចំការមន រាជធានីភ្នំពេញ។ នគរបាល តាមពាក្យបណ្តឹង បានឃាត់ខ្លួនជនជាប់ចោទ ក្នុងថ្ងៃដដែល និងបានដកហូតយកម៉ូតូមកវិញ។ អង្គហេតុនេះ ត្រូវបានចាត់ជាបទលួចមានស្ថានទម្ងន់ តាមមាត្រា៣៥៣និង៣៥៧នៃក្រមព្រហ្មទណ្ឌ ដែលទោសទណ្ឌមានពី៣ឆ្នាំទៅ១០ឆ្នាំក្នុងពន្ធនាគារ។ សាលាដំបូងរាជធានីភ្នំពេញ បានចេញសាលក្រមលេខ២៩៥(២០១៦) ផ្តន្ទាទោសជនជាប់ចោទអាយុ២១ឆ្នាំ ដាក់ពន្ធនាគារ៣ឆ្នាំ។ ជនជាប់ចោទ បានប្តឹងឧទ្ធរណ៍ប្រឆាំងសាលក្រមទាំងមូល ក៏ប៉ុន្តែក្នុងសវនាការ បានសុំបន្ថយទោស ដោយអះអាងថាគាត់សារភាពទទួលកំហុស...។ ព្រះរាជអាជ្ញាអមមហាអយ្យការសាលាឧទ្ធរណ៍ អះអាងថា ទោសនេះគឺក្នុងកម្រិតអប្បបរមាទៅហើយ។សាលាឧទ្ធរណ៍ បានចេញសាលដីកាលេខ៣៦ឆ្នាំ២០១៧ តម្កល់សាលក្រមលេខ២៩៥។

*៥.....សាលាដំបូងរាជធានីភ្នំពេញបានលើកយកសំអាងហេតុ និងសេចក្តីសម្រេចមកនេះ មានលក្ខណៈត្រឹមត្រូវតាមច្បាប់រួចហើយ ...*។

### ២. កំណត់សំគាល់

**ក.**សាលក្រមត្រូវមានសំអាងហេតុ (មាត្រា៣៥៧នៃក្រមនីតិវិធីព្រហ្មទណ្ឌ) តុលាការជាន់ខ្ពស់គាំទ្រសំអាងហេតុសាលាជាន់ទាប ដោយមិនចាំបាច់សរសេរឡើងវិញក៏បាន។ នេះជាការអនុវត្តកន្លងមក។ **ខ.** ការគាស់ទម្លុះទម្លាយ ជាកត្តាស្ថានទម្ងន់ទោស ត្រូវបានផ្តល់ន័យក្នុងមាត្រា៧៩នៃក្រមព្រហ្មទណ្ឌ។ ជនជាប់ចោទបានសារភាពថាលួច តែថាមិនគាស់ទម្លុះទេ គឺចូលតាមទ្វារបង្អួចចំហ។ **គ.** គិតចាប់ពីឆ្នាំកើតហេតុ ២០១៥ ខែធ្នូ មកដល់ថ្ងៃសាលដីកា (ខែឧសភា ឆ្នាំ២០១៧) មានរយៈពេលជិត២ឆ្នាំ។